ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៥៩៩...សហវ.ក.ត៧

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១១

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ:** ករណីសំណើសុំបុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារជួសជុលប្រព័ន្ធស្រោចស្រពទំនប់អាងទឹកអូរខ្លុង ស្ថិតក្នុងឃុំស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ ០៤២ ធទឧ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមប្រតិភូជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឲ្យក្រសួងធនធានទឹកនិងឧតុនិយម បុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ចំនួន ១.៦០០.០០០.០០០រៀល (មួយពាន់ប្រាំមួយរយលានរៀលគត់) ជូននាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារជួសជុលប្រព័ន្ធស្រោចស្រពទំនប់អាងទឹកអូរខ្លុង ស្ថិតក្នុងឃុំស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង មានដូចខាងក្រោម ៖

| | |
|---|---|
| -ជួសជុលទំនប់អូរខ្លុង ប្រវែង ៩៥៥ម | |
| -ស្តារប្រឡាយមេ ០១ខ្សែ ប្រវែង ៤.៨៥០ម | |
| -សាងសង់សំណង់លូជ្រុងបញ្ចេញទឹក(ទ្វារ០១) លើទំនប់អូរខ្លុង | ចំនួន ០២កន្លែង |
| -សាងសង់សំណង់បង្ហៀរ(ទ្វារ០១) លើទំនប់អូរខ្លុង | ចំនួន ០២កន្លែង |
| -សាងសង់សំណង់ប្រឡាយបេតុង លើទំនប់អូរខ្លុង ប្រវែង ១០០ម | |
| -សាងសង់សំណង់លូមូលឆ្លងផ្លូវ(ទ្វារ០១) លើប្រឡាយមេខ្សែទី ១ | ចំនួន ០១កន្លែង |
| -សាងសង់សំណង់លូមូល(ទ្វារ០១) លើប្រឡាយមេខ្សែទី ១ | ចំនួន ០១កន្លែង |
| សាងសង់សំណង់ស្ពាក់ទឹក លើប្រឡាយមេខ្សែទី ១ | ចំនួន ០១កន្លែង |

ខ្ទង់ប្រាក់បុរេប្រទាននេះ នឹងត្រូវទូទាត់ដោយឥណទានថវិការបស់ក្រសួងធនធានទឹកនិងឧតុនិយម ដោយអាណត្តិបើកប្រាក់ឲ្យបានទាន់ពេលវេលា ។

សូមឯកឧត្តមប្រតិភូទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com